មករា-មិថុនា ២០១៧

# ព្រឹត្តិបត្រព័ត៌មានហ្វុនប៉ាម

## អំពីវេទិកា

### ហ្វុនប៉ាម និងឌីហ្វុនប៉ាម

វេទិកាហ្វុនប៉ាម និងឌីហ្វុនប៉ាម គឺជាវេទិការួមគ្នានៃបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (Forum of Networks of PLHIV and MARPs "FoNPAMs" and District-Forum of Networks of PLHIV and MARPs "DFoNPAMs")។ វេទិកានេះរួមមាន សមាជិកជាតំណាងក្រុមស្ត្រីធ្វើការនៅតាមគ្រឹះស្ថានកម្សាន្ត ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន ក្រុមបុរសស្រឡាញ់បុរស ក្រុមអ្នកបំប្លែងភេទ និងក្រុមអ្នករស់នៅជាមួយមេរោគអេដស៍។ តំណាងទាំងអស់នឹងសហការណ៍លើការងារផ្នែកសុខភាព សិទ្ធិ ស្វែងរកការគាំទ្រ និងកិច្ចគាំពារផ្នែកសង្គម និងជាពិសេស ដើម្បីរួមចំណែកអោយសំរេចបាននូវគោលដៅ ៩០ ៩០ ៩០ ត្រឹមឆ្នាំ២០២០ របស់ប្រទេសកម្ពុជាផងដែរ។ ក្រោមជំនួយពីគំរូនៃការផ្តល់មូលនិធិថ្មីរបស់មូលនិធិសកល (Global Fund New Funding Model) គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាពហៅកាត់ថា HACC ជាលេខាធិការដ្ឋានសម្របសម្រួលវេទិកាហ្វុនប៉ាម និងឌីហ្វុនប៉ាមក្រោមគម្រោងពង្រឹងប្រព័ន្ធសហគមន៍ ដែលមានគោលបំណងពង្រឹងដល់បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ និងបណ្តាញក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍។

HACC | បណ្តាញអង្គការសង្គមស៊ីវិល វិស័យសុខាភិបាល

គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព

## មាតិកា


01 អំពីវេទិកាហ្វុនប៉ាម និងឌីហ្វុនប៉ាម

02 វឌ្ឍនៈភាព និងសកម្មភាពរបស់ហ្វុនប៉ាមនិងឌីហ្វុនប៉ាម
- ការជ្រើសរើសតំណាង និងបង្កើត វេទិកាឌីហ្វុនប៉ាម
- ចុះប្រមូល និងកត់ត្រាបញ្ហាដែលកើតមាននៅក្នុងសហគមន៍
- កិច្ចប្រជុំប្រចាំត្រីមាសរបស់ឌីហ្វុនប៉ាម
- កិច្ចប្រជុំប្រចាំត្រីមាសរបស់ហ្វុនប៉ាមថ្នាក់ជាតិ
- កិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆមាសជាមួយដៃគូពាក់ព័ន្ធ

04 ការរួមចំណែករបស់តំណាងហ្វុនប៉ាម និងឌីហ្វុនប៉ាម
- កិច្ចប្រជុំពិគ្រោះយោបល់ពីគម្រោងសំណើរថវិកាទៅមូលនិធិសកល
- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រៀងគម្រោងសំណើរថវិកាមូលនិធិសកល
- វគ្គបណ្តុះបណ្តាលស្តីពីការចងក្រងនិងរាយការណ៍ករណី
- ជ័យលាភីក្នុងការប្រកួតប្រជែងការសរសេរ និងនិយាយ

06 ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ហ្វុនប៉ាម និងឌីហ្វុនប៉ាម

06 ផែនការបន្តសំរាប់ ៦ខែ (កក្កដា-ធ្នូ ២០១៧)

06 ថ្លែងអំណរគុណចំពោះអង្គការដែលបានសហការណ៍


**បណ្តាញសមាជិកស្ថាបនិក:**

# វឌ្ឍនៈភាព និងសកម្មភាពរបស់ហ្វុនប៉ាម និងឪហ្វុនប៉ាម

## ការជ្រើសរើសតំណាង និងបង្កើតវេទិកាឪហ្វុនប៉ាម

សរុបចំនួន៣៣វេទិកាឪហ្វុនប៉ាមប្រចាំនៅ៣៣ស្រុកប្រតិបត្តិដែលមានអត្រាប្រឈមមុខខ្ពស់ក្នុងការចម្លងមេរោគអេដស៍ ( 33 Hotspot ODs )។




## ចុះប្រមូល និងកត់ត្រាបញ្ហាដែលកើតមាននៅក្នុងសហគមន៍



សរុបចំនួន៤១៦ករណីនៃការចុះប្រមូល និងកត់ត្រាបញ្ហាដែលកើតមាននៅក្នុងសហគមន៍ ដែលបានអនុវត្តដោយ វេទិកាឪហ្វុនប៉ាម ដែលជាតំណាងក្រុមទាំង៥ រួមមានតំណាង ក្រុមស្ត្រីធ្វើការនៅតាមគ្រឹះស្ថានកម្សាន្ត ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន ក្រុមបុរសស្រឡាញ់បុរស ក្រុមអ្នកបំឡែងភេទ និងក្រុមអ្នករស់នៅជាមួយមេរោគអេដស៍។ តំណាងវេទិកាឪហ្វុនប៉ាមត្រូវបានគាំទ្រអោយចុះជួបសួរសុខទុក្ខ ប្រមូល និងតក់ត្រាព័ត៌មានឬបញ្ហាអំពីសមាជិកនៅក្នុងសហគមន៍ ដើម្បីពិភាក្សារាល់កិច្ចប្រជុំប្រចាំត្រីមាស និងកិច្ចប្រជុំផ្សេងៗទៀតជាមួយអ្នកពាក់ព័ន្ធ ក្នុងគោលបំណងស្វែងរកការគាំទ្រ និងដំណោះយស្រាយសមរម្យ។

## កិច្ចប្រជុំប្រចាំត្រីមាសរបស់ឪហ្វុនប៉ាម



មកត្រឹមបច្ចុប្បន្ននេះសរុប៩៤ប្រជុំប្រចាំត្រីមាសជាមួយតំណាងវេទិកាឪហ្វុនប៉ាមក្នុង៣៣ស្រុកប្រតិបត្តិ ដែលបានរៀបចំ និងសម្របសម្រួលដោយប្រធានតំណាងវេទិកាឪហ្វុនប៉ាម។ កិច្ចប្រជុំប្រចាំត្រីមាសរបស់តំណាងវេទិកាឪហ្វុនប៉ាម គឺជាវេទិកាមួយ ដើម្បីចែករំលែកព័ត៌មានបញ្ហានិងការព្រួយបារម្ភផ្សេងៗ របស់អ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់នឹងមេរោគអេដស៍ ដែលបានប្រមូល និងតក់ត្រាតំណាងវេទិកាឪហ្វុនប៉ាមនីមួយៗ ។

## កិច្ចប្រជុំប្រចាំត្រីមាសរបស់ហ្វុនប៉ាមថ្នាក់ជាតិ



កិច្ចប្រជុំប្រចាំត្រីមាសរបស់ហ្វុនប៉ាមថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធលើកទី០៩ និងលើកទី១០ ត្រូវបានរៀបចំឡើងនៅការិយាល័យរបស់ **HACC** ក្នុងរយៈពេល៦ខែកន្លងនេះ ( មករា ដល់មិថុនា ឆ្នាំ ២០១៧ )។ កិច្ចប្រជុំប្រចាំត្រីមាសរបស់ហ្វុនប៉ាមថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធទាំងពីរលើកខាងលើនេះ បានរៀបចំឡើងដើម្បីធ្វើបច្ចុប្បន្នភាព និងដំណើរការនៃការអនុវត្តន៍សកម្មភាពរបស់វេទិកាហ្វុនប៉ាម និងឪហ្វុនប៉ាម បានពិភាក្សាបញ្ហាដែលជួបប្រទះ ជាពិសេសក៏បានពិនិត្យ និងពិភាក្សាអំពីគម្រោងសំណើរថ្មី ដែលបានដាក់ជូនមូលនិធិសកលសម្រាប់ឆ្នាំ២០១៨ ដល់ ២០២០។ សមាជិកហ្វុនប៉ាមថ្នាក់ជាតិ រួមទាំងអ្នកពាក់ព័ន្ធដែលអញ្ជើញមកពីស្ថាប័នដូចជា **CPN+, AUA, Korsang, WNU, Smart Girl, BC, CNPUD, NNEW, CPU, UNAIDS, CCC, KHANA** និង **FHI360** បានអញ្ជើញចូលរួម។

## កិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆមាសជាមួយដៃគូពាក់ព័ន្ធ



កិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆមាសជាមួយសមាជិកហ្វុនប៉ាម ឪហ្វុនប៉ាម និងអ្នកពាក់ព័ន្ធ ត្រូវបានរៀបចំជាលើកទី៣នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ នៅសាលប្រជុំសណ្ឋាគារភ្នំពេញក្នុងរាជធានីភ្នំពេញ។ កិច្ចប្រជុំនេះ គឺជាវេទិកាថ្នាក់ជាតិមួយ ដែលផ្តល់ឱកាសជាពិសេសសម្រាប់តំណាងវេទិកាឪហ្វុនប៉ាម និងតំណាងហ្វុនប៉ាមធ្វើការរួមគ្នាដោយប្រមូលផ្តុំ និងចែករំលែកព័ត៌មាន បញ្ហាប្រឈមរវាងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ជាពិសេសជាងនេះទៅទៀត វាជាវេទិកាដើម្បីស្វែងរកការគាំទ្រ និងស្វែងរកដំណោះស្រាយពីស្ថាប័នពាក់ព័ន្ធ និងស្ថាប័នជាតិ ដោយតំណាងសហគមន៍ទាំងអស់លើកឡើងនូវបញ្ហាទាំងនោះនៅក្នុងវេទិកពិភាក្សាតុមូលជាមួយវាគ្មិនកិត្តយស ដែលបានអញ្ជើញចូលរួមមានតំណាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ **(NAA)** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ **(NCHADS)** និងតំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **(NACD)** ។

បញ្ហាសំខាន់ៗរបស់សហគមន៍ដែលបានលើកឡើងដាក់ជូនវាគ្មិនមានដូចជា៖

| បញ្ហារបស់ក្រុម EW | បញ្ហារបស់ក្រុម MSM/TG |
|---|---|
| ▫ ការបង្ខិតបង្ខំអោយស្ត្រីញាំស្រាពីសំណាក់ម្ចាស់ហាង និងភ្ញៀវ<br>▫ ការចាប់ និងគំរាមពីបទជួញដូរមនុស្ស និងផ្លូវភេទ និងគ្រឿងញៀន<br>▫ ស្ត្រីមួយចំនួនធ្លាក់ខ្លួនប្រើប្រាស់សារជាតុញៀន | ▫ ការម៉ាក់ងាយរើសអើងនៅតែមានចំពោះពួកគាត់ពីសំណាក់ប៉ូលីស អាជ្ញាធរ អ្នកផ្តល់សេវា សង្គម និងគ្រួសារ<br>▫ សព្វថ្ងៃមិនមានកម្មវិធីជាតិ ឬក្រោមជាតិណាអនុវត្តសកម្មភាពផ្តោតលើក្រុម MSM/TG ក្រោម ១៨ឆ្នាំ<br>▫ មិនទាន់មានសេវាសុខភាពគ្រប់គ្រាន់ និងមិនយកថ្លៃសេវាចំពោះMSM/TG ជាពិសេសសេវាកាមរោគ |

| បញ្ហារបស់ក្រុម PWID/PWUD | បញ្ហារបស់ក្រុម PLHIV |
|---|---|
| ▫ ការចាប់ខ្លួនអ្នកប្រើប្រាស់ ហើយចោទពីបទចែកចាយ និងជួញដូរគ្រឿងញៀន (មិនច្បាស់ពីកំរិត និងនិយមន័យអ្នកប្រើប្រាស់ ឬអ្នកជួញដូរ)<br>▫ សេវាបន្សាបគ្រឿងញៀន ដោយមេតាដូនត្រូវបង់ប្រាក់ សម្រាប់ការចុះឈ្មោះដំបូង $16 និងប្រចាំថ្ងៃ $1 ទៀត<br>▫ ការរើសអើងមិនព្រមទទួលអោយធ្វើការដូចគេដូចឯង | ▫ PLHIV ដែលចំណាក់ស្រុកជួបប្រទះបញ្ហាក្នុងការមកបើកថ្នាំ (យឺតយ៉ាវថ្ងៃណាត់, ប្រើប្រាស់មិនទៀងទាន់, ដាច់ថ្នាំ ពេទ្យដាក់ពិន័យដោយបើកអោយតែ១សប្តាហ៍.......)<br>▫ ថ្នាំព្យាបាលជម្ងឺឱកាសនិយមមិនគ្រប់គ្រាន់តាមតម្រូវការ<br>▫ ស្ថានភាពសកម្មភាព កម្មវិធីជាមួយ PLHIV ថយចុះ តែស្ថានភាពរបស់អ្នកជំងឺ (ការឆ្លង, ការស្លាប់, បោះបង់ថ្នាំ, សុខភាពចុះខ្សោយ....) ហាក់ដូចកើនឡើង |

# ការរួមចំណែករបស់តំណាងហ្វុនប៉ាម និងឌីហ្វុនប៉ាម

## កិច្ចប្រជុំពិគ្រោះយោបល់ពីគម្រោងសំណើរថវិកាទៅមូលនិធិសកល



តំណាងឌីហ្វុនប៉ាម ដែលជាតំណាងសហគមន៍ និងតំណាងអង្គការសង្គមស៊ីវិលសរុបប្រមាណ ៨០នាក់ បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ក្នុងគោលបំណងដើម្បីប្រមូលនូវព័ត៌មានយុទ្ធសាស្ត្រ និងចំណុចជាអាទិភាពសម្រាប់រៀបចំសំណើរថវិកា ទៅមូលនិធិសកលសម្រាប់កម្មវិធីអេដស៍សម្រាប់ឆ្នាំ២០១៨-២០២០ ដើម្បីរួមចំណែកក្នុងការឈានទៅរក ការលប់បំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅឆ្នាំ ២០២៥។ កិច្ចប្រជុំពិគ្រោះយោបល់នេះត្រូវបានសហការណ៍រៀបចំឡើងរយៈពេលមួយថ្ងៃពេញនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៧ នៅសណ្ឋាគារវិមានបៃតង រាជធានីភ្នំពេញ ដោយលេខាធិការដ្ឋាន HACC និង CPN+ ។

## កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រៀងគម្រោងសំណើរថវិកាមូលនិធិសកល

តាមរយៈកិច្ចសហការណ៍ជាមួយ HACC, CPN+ និង KHANA កិច្ចប្រជុំពិគ្រោះយោបល់និងពិនិត្យមើលលើសេចក្តីព្រៀងគម្រោងសំណើរថវិកាមូលនិធិសកលត្រូវបានរៀបចំឡើងរយៈពេលមួយថ្ងៃពេញនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។



តំណាងឌីហ្វុនប៉ាម ដែលជាតំណាងសហគមន៍ និងតំណាងអង្គការសង្គមស៊ីវិលសរុបប្រមាណជិត ១០០នាក់ បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ក្នុងគោលបំណងដើម្បីពិនិត្យមើលលើសេចក្តីព្រៀង គម្រោងសំណើរថវិកាទៅមូលនិធិសកល សម្រាប់កម្មវិធីអេដស៍សម្រាប់ឆ្នាំ ២០១៨-២០២០។

## វគ្គបណ្តុះបណ្តាលស្តីពីការចងក្រង និងរាយការណ៍ករណី

តំណាងឌីហ្វុនប៉ាមក្នុង ១៩ស្រុកប្រតិបត្តិត្រូវបានអញ្ជើញអោយចូលរួមក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីការចងក្រង និងរាយការណ៍ករណីនៅក្នុងសហគមន៍។ វគ្គបណ្តុះបណ្តាលមានរយៈពេល ២ថ្ងៃគឺ២៣ និង២៤ ខែកុម្ភៈ ឆ្នាំ២០១៧ នៅសណ្ឋាគារដារ៉ាអ៊ែរផតរាជធានីភ្នំពេញ ដែលរៀបចំឡើងដោយ អង្គការ KHANA។



## ជ័យលាភីក្នុងការប្រកួតប្រជែងការសរសេ និងនិយាយ

សូមចូលរួមអបអរសាទរចំពោះសមាជិកឌីហ្វុនប៉ាម ដែលបានចូលរួម និងទទួលបានជ័យលាភីក្នុងការប្រកួតប្រជែងការសរសេ និងនិយាយលើប្រធានបទ "តើហេតុអ្វីបានជាអ្នកគិតថាបញ្ហាសិទ្ធិមនុស្សមានសារៈសំខាន់សម្រាប់ក្រុមគោលដៅត្រូវដឹង?" ក្រោមគម្រោង LINKAGES ។ សូមលើកទឹកចិត្តចំពោះតំណាងឌីហ្វុនប៉ាម និងសហគមន៍ទាំងអស់គ្នាអោយចូលរួមបញ្ចេញសមត្ថភាពទាំងអស់គ្នា។



## ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ហ្វុនប៉ាម និងឌីហ្វុនប៉ាម

លេខាធិការដ្ឋាន HACC ដែលកំពុងសម្របសម្រួលវេទិកាហ្វុនប៉ាម និងឌីហ្វុនប៉ាមបានរៀបចំជាប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ហ្វុនប៉ាម និងឌីហ្វុនប៉ាម។ វាជាប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅក្នុងវេបសាយ (Online) ដែលត្រូវបានបង្កើតឡើងក្នុងវេបសាយរបស់ HACC http://hacccambodia.org/fonpam/ ។ ទិន្នន័យមួយចំនួនត្រូវបានបំពេញ ហើយទិន្នន័យមួយចំនួនទៀត កំពុងតែដំណើរការប្រមូលតាមរយៈតំណាងឌីហ្វុនប៉ាមទាំង៣៣ស្រុកប្រតិបត្តិ ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ហ្វុនប៉ាម និងឌីហ្វុនប៉ាម រួមមាន៖

1. សមាជិកហ្វុនប៉ាម FoNPAMs
2. សមាជិកឌីហ្វុនប៉ាម DFoNPAMs
3. អង្គការធ្វើការជាមួយ PLHIV និង KAPs
4. ចំនួន PLHIV និង KAPs
5. បញ្ជីទំនាក់ទំនងCMC និងCMA
6. អ្នកផ្តល់សេវាផ្នែកច្បាប់
7. កម្រងករណី
8. បញ្ហារបស់ PLHIV និង KAPs
9. ព្រឹត្តិការណ៍ និងសកម្មភាព

## ផែនការបន្តសំរាប់បីខែ (កក្កដា-ធ្នូ ២០១៧)

- តំណាងឌីហ្វុនប៉ាមអនុវត្តសកម្មភាពការចុះជួបសួរសុខទុក្ខ និងប្រមូលព័ត៌មានពីសមាជិក
- កិច្ចប្រជុំប្រចាំត្រីមាសជាមួយសមាជិកឌីហ្វុនប៉ាម
- កិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាយោបល់
- គាំទ្រដល់ការត្រួតពិនិត្យមើលឡើងវិញនូវគោលនយោបាយរបស់បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ និង ក្រុមប្រឈមមុខខ្ពស់
- គាំទ្រកិច្ចប្រជុំប្រចាំត្រីមាសគណៈគ្រប់គ្រងរបស់បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ និង ក្រុមប្រឈមមុខខ្ពស់
- គាំទ្រកិច្ចប្រជុំប្រចាំឆ្នាំគណៈគ្រប់គ្រងរបស់បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ និង ក្រុមប្រឈមមុខខ្ពស់
- ការសិក្សាវាយតម្លៃអំពីការអនុវត្តន៍គម្រោងដោយធៀបនឹងលទ្ធផល
- ប្រជុំប្រចាំឆមាសរវាងអ្នកពាក់ព័ន្ធ និងតំណាងហ្វុនប៉ាម និងឌីហ្វុនប៉ាម
- ចុះពង្រឹងសមត្ថភាព និងការអនុវត្តន៍សកម្មភាពរបស់ឌីហ្វុនប៉ាមនៅមូលដ្ឋាន

សហការណរៀបចំ និងចងក្រងដោយ HACC និង UNAIDS
ឧបត្ថម្ភថវិកាដោយ GFATM តាមរយៈ HACC

សូមថ្លែងអំណរគុណចំពោះអង្គការ AHF, BSDA, CPN+, CPR, CWPD, KHEMARA, KOSHER, MHSS, MHC, PC, PFD, PSOD, REDA, SIT, WOMEN និងWOSO ដែលមានកិច្ចសហការណ៍យ៉ាងល្អជាមួយគ្នាក្នុងការជ្រើសរើសតំណាងក្រុមប្រឈមមុខខ្ពស់ និងតំណាងអ្នករស់នៅជាមួយមេរោគអេដស៍ ក្នុងការធ្វើជាសមាជិកឌីហ្វុនប៉ាមនៅស្រុកប្រតិបត្តិទាំង៣៣ ។

សូមថ្លែងអំណរអរគុណចំពោះ FHI360 (គម្រោងLinkages), HACC, KHANA និង UNAIDS ដែលបានចូលរួមជាការផ្តល់ជាជំនួយបច្ចេកទេស និងថវិកាសម្រាប់ការពង្រឹងបណ្តាញសហគមន៍ទាំងអស់នោះនៅក្នុងប្រទេសកម្ពុជា។